**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០០១ សណន.

ថ្ងៃ អង្គារ ៦កើត ខែ មាឃ ឆ្នាំ ជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២១

# សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យទេសចរណ៍នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

អនុលោមអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃ០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង អនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃ០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ និងអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃ០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក រាជរដ្ឋាភិបាលបានប្រគល់មុខងារជូនរដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យទទួលខុសត្រូវក្នុងការអនុវត្តមុខងារផ្តល់សេវារដ្ឋបាលក្នុងវិស័យទេសចរណ៍ រួមមាន៖

១. ផ្ទះសំណាក់ ឬផ្ទះភ្ញៀវចំណុះត្រឹម ៨ (ប្រាំបី) បន្ទប់ចុះក្រោម
២. បន្ទប់ជួល
៣. ផ្ទះមានបន្ទប់ជួល
៤. អាហារដ្ឋាន និងភោជនីយដ្ឋានទេសចរណ៍ចាប់ពី៥០ (ហាសិប) នាក់/កៅអីចុះក្រោម (លើកលែងតែមានលក្ខណៈស្តង់ដារ ឬម្ចាស់អាជីវកម្មជាជនបរទេស)
៥. អាហារដ្ឋាន និងភោជនីយដ្ឋានក្នុងស្រុកចាប់ពី ៥០ (ហាសិប)នាក់/កៅអីចុះក្រោម (ដូចជាតូបលក់អាហារ ហាងលក់គុយទាវ កាហ្វេ ហាងលក់ស៊ុប និងហាងលក់សាច់អាំង...)
៦. មធ្យោបាយដឹកជញ្ជូនទេសចរណ៍ រួមមានរថយន្តដឹកទេសចរណ៍ចាប់ពី០៥កៅអីចុះក្រោម ម៉ូតូឌុបទេសចរណ៍ ម៉ូតូជួលទេសចរណ៍ ឬម៉ឺក់ម៉ូតូទេសចរណ៍
៧. ខារ៉ាអូខេចាប់ពី០៥បន្ទប់ចុះក្រោម
៨. ម៉ាស្សាសុខភាពចាប់ពី០៥គ្រែ ឬ០៥កៅអីចុះក្រោម និង
៩. ស្នូកឃ័រចាប់ពី០៥តុចុះក្រោម។

ដើម្បីធានាដល់ប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តមុខងារខាងលើ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដូចខាងក្រោម៖

## ១- ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ សម្រាប់ការផ្តល់អាជ្ញាបណ្ណទេសចរណ៍

### ១.១. ការស្នើសុំសម្រាប់អាជីវកម្មបើកថ្មី

ប្រភេទសេវារដ្ឋបាលក្នុងវិស័យទេសចរណ៍ ដែលត្រូវស្នើសុំបើកអាជីវកម្មថ្មី រួមមាន៖



អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

- **សេវាស្នាក់នៅ៖** រួមមាន ផ្ទះសំណាក់ ឬផ្ទះភ្ញៀវ ចំណុះត្រឹម៨(ប្រាំបី)បន្ទប់ចុះក្រោម បន្ទប់ជួល និងផ្ទះមានបន្ទប់ជួល
- **សេវាម្ហូបអាហារ៖** រួមមានអាហារដ្ឋាន ភោជនីយដ្ឋានទេសចរណ៍ចាប់ពី៥០(ហាសិប) នាក់/កៅអីចុះក្រោម ( លើកលែងតែមានលក្ខណៈស្តង់ដារ ឬម្ចាស់អាជីវកម្មជាជនបរទេស) និងអាហារដ្ឋាន ភោជនីយដ្ឋានក្នុងស្រុកចាប់ពី៥០(ហាសិប) នាក់/កៅអីចុះក្រោម ដូចជា តូបលក់អាហារ ហាងលក់គុយទាវ តូបលក់កាហ្វេ ហាងលក់ស៊ុប និងសាច់អាំង...
- **សេវាខារ៉ាអូខេ៖** ខារ៉ាអូខេចាប់ពី០៥ (ប្រាំ) បន្ទប់ចុះក្រោម
- **សេវាម៉ាស្សាសុខភាព៖** ម៉ាស្សាសុខភាពចាប់ពី ០៥ គ្រែ ឬកៅអីចុះក្រោម
- **សេវាស្នូកឃ័រ៖** ស្នូកឃ័រចាប់ពី០៥(ប្រាំ)តុចុះក្រោម
- **សេវាដឹកជញ្ជូន៖** រួមមានរថយន្តដឹកជញ្ជូនភ្ញៀវទេសចរចាប់ពី០៥កៅអីចុះក្រោម ម៉ូតូឌុបទេសចរណ៍ ម៉ូតូជួលទេសចរណ៍ និងរ៉ឺម៉កម៉ូតូដឹកទេសចរណ៍ ។

ការស្នើសុំ និងសំណុំឯកសារភ្ជាប់សម្រាប់សេវារដ្ឋបាលខាងលើនេះត្រូវអនុវត្តដូចខាងក្រោម៖

- ប្រភេទសេវាស្នាក់នៅ សេវាម្ហូបអាហារ សេវាខារ៉ាអូខេ សេវាម៉ាស្សាសុខភាព និងសេវាស្នូកឃ័រ ត្រូវបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖
  - ពាក្យស្នើសុំ
  - អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរថតចម្លង (សម្រាប់ប្រជាពលរដ្ឋខ្មែរ) ឬលិខិតឆ្លងដែនថតចម្លង(សម្រាប់ជនបរទេស) ដែលមានការបញ្ជាក់ពីអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច ឬមានការផ្តិតស្នាមមេដៃទទួលស្គាល់ដោយសាមីខ្លួន ចំនួន ០១ច្បាប់
  - រូបថតបច្ចុប្បន្នរបស់ប្រតិបត្តិករទេសចរណ៍ ៤x៦ ចំនួន ០៣សន្លឹក
  - គំនូសបំព្រួញទីតាំង និងរូបថតអគារធ្វើអាជីវកម្ម
  - រូបថតបង្ហាញប្រព័ន្ធបង្ការ និងពន្លត់អគ្គីភ័យ ក្នុងទីតាំងអាជីវកម្ម
  - កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ចំនួន ០១ច្បាប់។
- ប្រភេទសេវារថយន្តដឹកជញ្ជូនភ្ញៀវទេសចរចាប់ពី០៥កៅអីចុះក្រោមត្រូវបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ ដូចខាងក្រោម ៖
  - ពាក្យស្នើសុំ
  - អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរថតចម្លង (សម្រាប់ប្រជាពលរដ្ឋខ្មែរ) ឬលិខិតឆ្លងដែនថតចម្លង(សម្រាប់ជនបរទេស) ដែលមានការបញ្ជាក់ពីអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច ឬមានការផ្តិតស្នាមមេដៃទទួលស្គាល់ដោយសាមីខ្លួន ចំនួន ០១ច្បាប់
  - រូបថតបច្ចុប្បន្នរបស់ប្រតិបត្តិករទេសចរណ៍ ៤x៦ ចំនួន ០៣សន្លឹក
  - កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ ចំនួន ០១ច្បាប់
  - បណ្ណសម្គាល់ម្ចាស់យានយន្តថតចម្លង (បញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ចំនួន ០១ច្បាប់។

- ដោយឡែកសម្រាប់ការស្នើសុំសេវាម៉ូតូឌុបទេសចរណ៍ ម៉ូតូជួលទេសចរណ៍ និងរ៉ឺម៉កម៉ូតូដឹកទេសចរណ៍ ត្រូវបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ដូចខាងក្រោម ៖
  - ពាក្យស្នើសុំ
  - អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរថតចម្លង ដែលមានការបញ្ជាក់ពីអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច ឬមានការផ្ដិតស្នាមមេដៃទទួលស្គាល់ដោយសាមីខ្លួន ចំនួន ០១ច្បាប់
  - រូបថតបច្ចុប្បន្នរបស់ប្រតិបត្តិករទេសចរណ៍ ៤x៦ ចំនួន ០៣សន្លឹក
  - បណ្ណសម្គាល់ម្ចាស់យានយន្តថតចម្លង(បញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច) ចំនួន ០១ច្បាប់។

**១.២. ការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណទេសចរណ៍**

ការស្នើសុំបន្តអាជ្ញាបណ្ណប្រកបអាជីវកម្មទេសចរណ៍គ្រប់ប្រភេទសេវាទាំងអស់ ដែលមានកំណត់នៅក្នុងចំណុច ១.១ខាងលើ ត្រូវបំពេញពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ ដូចខាងក្រោម៖

- ពាក្យស្នើសុំ
- អាជ្ញាបណ្ណទេសចរណ៍ឆ្នាំចុងក្រោយ (ថតចម្លង ) ចំនួន ០១ច្បាប់
- កិច្ចសន្យារបស់ប្រតិបត្តិករទេសចរណ៍ ចំនួន ០១ច្បាប់
- រូបថតបច្ចុប្បន្នរបស់ប្រតិបត្តិករទេសចរណ៍ ៤x៦ ចំនួន ០៣សន្លឹក។

## ២- នីតិវិធីក្នុងការស្នើសុំអាជ្ញាបណ្ណទេសចរណ៍

ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬសុំបន្តអាជ្ញាបណ្ណទេសចរណ៍ និងមកទទួលអាជ្ញាបណ្ណទេសចរណ៍នៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលទីតាំងអាជីវកម្មនោះស្ថិតនៅ
- បន្ទាប់ពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់សម្រាប់ការស្នើសុំអាជ្ញាបណ្ណទេសចរណ៍ បុគ្គលិកជំនាញនៅការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចតទៅ ៖
  - ➢ ពិនិត្យភាពត្រឹមត្រូវលើពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាតាមគោលការណ៍កំណត់
    - ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់មិនទាន់ត្រឹមត្រូវ ឬមិនទាន់គ្រប់គ្រាន់ ត្រូវជូនដំណឹងទៅប្រតិបត្តិករទេសចរណ៍វិញតាមនីតិវិធីការអនុវត្តការងាររបស់ការិយាល័យច្រកចេញចូលតែមួយ
    - បើពិនិត្យឃើញថា ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ត្រឹមត្រូវ និងគ្រប់គ្រាន់ បុគ្គលិកជំនាញត្រូវអនុវត្តតាមនីតិវិធីនៃការផ្ដល់សេវាក្នុងវិស័យទេសចរណ៍ ដោយត្រូវត្រួតពិនិត្យវាយតម្លៃលក្ខណៈបច្ចេកទេសស្របតាមទម្រង់ប័ណ្ណត្រួតពិនិត្យ តាមប្រភេទសេវានីមួយៗ ដែលមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃសេចក្ដីណែនាំនេះ។

- បុគ្គលិកជំនាញត្រូវរៀបចំ"កំណត់បង្ហាញរឿង" ដោយពិនិត្យវាយតម្លៃ និងផ្តល់យោបល់បច្ចេកទេសលើប្រភេទសេវាដែលបានស្នើសុំនោះ ព្រមទាំងរៀបចំសេចក្តីព្រាងអាជ្ញាបណ្ណក្នុងករណីសំណើសុំនោះត្រូវបានអនុញ្ញាត ឬលិខិតឆ្លើយតបក្នុងករណីសំណើសុំមិនត្រូវបានអនុញ្ញាត រួចបញ្ជូនទៅប្រធានការិយាល័យច្រកចេញចូលតែមួយដើម្បីដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌ ឬអ្នកមានសិទ្ធិសម្រេចដើម្បីពិនិត្យ និងចុះហត្ថលេខា។

**៣. កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពអាជ្ញាបណ្ណទេសចរណ៍**

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាព ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តិដែលនៅជាធរមាន។

ប្រតិបត្តិករទេសចរណ៍ត្រូវមកដាក់ពាក្យស្នើសុំបន្តសុពលភាពអាជីវកម្មឱ្យបានមុន៣០ថ្ងៃនៃថ្ងៃផុតកំណត់សុពលភាពអាជ្ញាបណ្ណទេសចរណ៍។

ក្នុងករណីប្តូរម្ចាស់អាជ្ញាបណ្ណ ប្រតិបត្តិករទេសចរណ៍ត្រូវដាក់ពាក្យស្នើសុំប្តូរម្ចាស់អាជ្ញាបណ្ណឱ្យបានយ៉ាងតិច៣០ (សាមសិប)ថ្ងៃមុនថ្ងៃចាប់ផ្តើមអាជីវកម្ម។

ក្នុងករណីប្តូរទីតាំងអាជីវកម្ម ប្រតិបត្តិករទេសចរណ៍ត្រូវជូនដំណឹងជាលាយលក្ខអក្សរយ៉ាងតិច៣០ (សាមសិប)ថ្ងៃមុនថ្ងៃចាប់ផ្តើមសកម្មភាពអាជីវកម្មនៅទីតាំងថ្មីនោះ (ករណីនេះ មិនតម្រូវឱ្យបង់ថ្លៃសេវា)។

ចំពោះការបិទអាជីវកម្ម ប្រតិបត្តិករទេសចរណ៍ត្រូវដាក់ពាក្យស្នើសុំបិទអាជីវកម្ម ឱ្យបានយ៉ាងតិច៣០ (សាមសិប)ថ្ងៃមុនថ្ងៃបិទអាជីវកម្ម ។ រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវចេញលិខិតបិទអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ១៥ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំបិទអាជីវកម្ម ដោយមិនតម្រូវឱ្យប្រតិបត្តិករទេសចរណ៍បង់កម្រៃសេវាឡើយ ។

**៤. ការគ្រប់គ្រង និងការបែងចែកចំណូល**

រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវរៀបចំឱ្យមានសម្រង់ព័ត៌មានទិន្នន័យអាជីវកម្ម សេវាកម្មក្នុងវិស័យទេសចរណ៍ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងត្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់យ៉ាងតិចមួយឆ្នាំម្តង។

ចំណូលដែលទទួលបានពីការផ្តល់សេវារដ្ឋបាលក្នុងវិស័យទេសចរណ៍នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**៥. សមត្ថកិច្ចគ្រប់គ្រងរបស់មន្ទីរទេសចរណ៍រាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ**

មន្ទីរទេសចរណ៍រាជធានី ខេត្ត មានភារកិច្ចទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលមន្ត្រីជំនាញ ណែនាំផ្នែកបច្ចេកទេស និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ក្នុងការអនុវត្តមុខងារដែលបានប្រគល់។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានភារកិច្ចក្នុងការចាត់ចែង និងអនុវត្តមុខងារផ្តល់សេវាទេសចរណ៍ដែលបានប្រគល់ ដូចតទៅ៖

- ទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកតាមគោលការណ៍ នីតិវិធី ស្តង់ដាសេវា និងធនធានដែលបានផ្ទេរ
- អនុវត្តតាមគោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង និងចាត់ចែងតាមការកំណត់របស់ក្រសួងទេសចរណ៍
- ក្នុងករណី ការអនុវត្តមុខងារដែលបានប្រគល់មួយចំនួនរបស់ក្រសួងទេសចរណ៍ មិនមាន

លក្ខណៈសមស្របតាមស្ថានភាពនៅក្នុងមូលដ្ឋានរបស់ខ្លួន រដ្ឋបាលក្រុង ស្រុក ខណ្ឌមានសិទ្ធិសម្រេច ឬស្នើសុំមកក្រសួងទេសចរណ៍ ដើម្បីកំណត់អំពីបទដ្ឋាន នីតិវិធី និងធនធានសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារទាំងនោះ

- ក្នុងករណីដែលប្រតិបត្តិករទេសចរណ៍មិនគោរពទៅតាមលក្ខខណ្ឌដែលបានកំណត់ ឬបើពិនិត្យឃើញថា ការបន្តប្រតិបត្តិការអាជីវកម្មលើមុខងារទាំងនោះបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរមកលើសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព រដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចលុប ឬព្យួរអាជ្ញាបណ្ណនោះជាបន្ទាន់ ដោយបញ្ជាក់ហេតុផលឱ្យបានច្បាស់លាស់។ ការលុប ឬការព្យួរអាជ្ញាបណ្ណនេះ មិនធ្វើឱ្យប្រតិបត្តិករទេសចរណ៍រួចផុតពីការទទួលខុសត្រូវចំពោះបទល្មើស និងទោសប្បញ្ញត្តិដែលបានកំណត់ក្នុងច្បាប់ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន
- ពិនិត្យ តាមដាន វាយតម្លៃជាប់ជាប្រចាំ ចំពោះមុខងារដែលបានប្រគល់ និងចាត់វិធានការទប់ស្កាត់បទល្មើសដែលអាចកើតមានឡើងក្នុងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍
- ធ្វើការត្រួតពិនិត្យ ឬដកហូតសិទ្ធិប្រកបអាជីវកម្ម សេវាកម្ម ឬស្នើសុំការសហការជាមួយមន្ទីរទេសចរណ៍រាជធានី ខេត្ត បើពិនិត្យឃើញថា សកម្មភាពអាជីវកម្មនោះខុសពីគោលការណ៍នៃច្បាប់។ ក្នុងករណីពិនិត្យឃើញថាសកម្មភាពអាជីវកម្មនោះមិនមានអាជ្ញាបណ្ណទេសចរណ៍ត្រូវមានវិធានការណ៍ធ្វើការណែនាំ និងព្រមានជាលាយល័ក្ខអក្សរដើម្បីឱ្យមកបំពេញបែបបទស្របតាមនីតិវិធី និងធ្វើការផាកពិន័យដោយអនុលោមទៅតាមប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនរដ្ឋបាលរាជធានី ខេត្ត ដើម្បីបូកសរុប និងរាយការណ៍ជូនក្រសួងទេសចរណ៍ ដោយចម្លងជូនក្រសួងមហាផ្ទៃ និងមន្ទីរទេសចរណ៍រាជធានីខេត្តស្របតាមគោលការណ៍កំណត់។

ទទួលបានសេចក្តីណែនាំនេះ អង្គភាពពាក់ព័ន្ធនានានៃក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍រាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គណៈកម្មការដឹកនាំការងារវិមជ្ឈការ វិសហមជ្ឈការក្រសួងទេសចរណ៍
- លេខាធិការដ្ឋានគណៈកម្មការដឹកនាំការងារវិមជ្ឈការ វិសហមជ្ឈការក្រសួងទេសចរណ៍
- រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ–កាលប្បវត្តិ